## ៥. ការគ្រប់គ្រងជំងឺ

នៅពេលដែលពិនិត្យឃើញមានជំងឺនេះ គេត្រូវធ្វើការព្យាបាលភ្លាមៗ ជំងឺនេះបំផ្លាញមែកខ្ចីនិងផ្នែកនៃដើមនៅត្រង់កន្លែងបែកមែកនិងធ្វើឲ្យខូចសំបកយ៉ាងធ្ងន់ធ្ងរហើយនិងអាចបណ្ដាលឲ្យងាប់មែកនិងងាប់ចុងទាំងស្រុងទៀតផង។

ការព្យាបាលដោយជោគជ័យគឺអាស្រ័យលើការធ្លាប់ដឹងភ្លាមៗ ចាប់តាំងពីផ្សិតកកើតដំបូង។ កាលណាផ្សិតកើតរុំជុំវិញមែករួចហើយមែកនឹងងាប់ **គេមិនអាចព្យាបាលវាបានទេ។** ត្រូវព្យាបាលដោយបាញ់ថ្នាំសម្លាប់ផ្សិតលើមែកឈើ ដោយប្រើឧបករណ៍ដែលមានដងវែងនិងក្បាលបាញ់សាច។

ប្រសិនបើជំងឺធ្ងន់ធ្ងរ គឺត្រូវកាត់មែកដែលកើតជំងឺឲ្យដល់ផ្នែកខាងក្រោមដែលគ្មានជំងឺប្រវែង ៣០ស.ម រួចយកទៅកប់ ឬដុតចោល។ ដើម្បីគ្រប់គ្រងជំងឺនេះ គេអាចបាញ់ថ្នាំសម្លាប់ផ្សិតដូចជា៖

-ល្បាយប័រដូ (Bordeaux Mixture) លើមែក ចំពោះដើម



ការបាញ់ថ្នាំ Validamycin



ឧបករណ៍ព្យាបាលជំងឺផ្កាកូលាប

កៅស៊ូ**មិនទាន់ចៀរជ័រ** ដែលត្រូវបាញ់ប្រវែង៣០-៥០ស.មផ្នែកខាងលើនិងខាងក្រោមកន្លែងដែលកើតជំងឺ។ ថ្នាំនេះហាមប្រើចំពោះដើមកៅស៊ូកំពុងចៀរជ័រ ព្រោះវាអាចធ្វើឲ្យប៉ះពាល់ដល់គុណភាពទឹកជ័រ។

- ទ្រីដឺម័ហ្វ (Tridemorph) នៅកំហាប់ 1%
- វ៉ាលីដាមីស៊ីន (Validamycin) នៅកំហាប់ 1.5% - 2%។

ការបាញ់ប្រព្រឹត្តទៅពី១០-១៤ថ្ងៃម្តង ហើយបាញ់ឲ្យបាន៣-៤ដងតាមភាពចាំបាច់ ចាប់ពីពេលកើតជំងឺ៕


**វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

អាសយដ្ឋានៈ អគារលេខ ៩ មហាវិថី ប៉ែននុត (២៨៩) សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ឬ ប្រអប់សំបុត្រលេខ ១៣៣៧ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៨៨២ ៨៣១

សារអេឡិចត្រូនិច : crri@camnet.com.kh

វិបសាយ : www.crri.com.kh



ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

ប័ណ្ណបច្ចេកទេស ២០១៣/០១


# ជំងឺផ្កាកូលាប
# Pink disease




ការផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា
ការិយាល័យដាំដុះនិងការពារ